# សុន្ទរកថា

## របស់អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ថ្លែងក្នុង

## ពិធី «ប្រកាសដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឯកសារឌីជីថលជំនាន់ទី ១ (FMIS Portal V1) នៅរដ្ឋបាលស្រុក និង រដ្ឋបាលឃុំ»

## ទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០២២

- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី;
- តំណាងដៃគូអភិវឌ្ឍន៍;
- អង្គពិធីជាទីមេត្រី !

ថ្ងៃនេះ, ខ្ញុំពិតជាមានក្តីសោមនស្សជាអនេក ដោយបានមកចូលរួមជាអធិបតី និង ថ្លែងសុន្ទរកថា នៅក្នុងពិធី **«ប្រកាសដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឯកសារឌីជីថលជំនាន់ទី ១ (FMIS Portal V1) នៅរដ្ឋបាលស្រុក និង រដ្ឋបាលឃុំ»** ។ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមានរបស់ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ជាថ្នាក់ដឹកនាំ, មន្ត្រីរាជការ និង តំណាងដៃគូអភិវឌ្ឍន៍ ដែលបានចូលរួមនៅក្នុងពិធីនាថ្ងៃនេះ, ទាំងនៅទីនេះផ្ទាល់ និង នៅតាមប្រព័ន្ធវីដេអូអនឡាញពីចម្ងាយ ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS ដែលបានផ្តល់នូវរបាយការណ៍យ៉ាងក្បោះក្បាយអំពីទិដ្ឋភាពរួម នៃដំណើរការអភិវឌ្ឍប្រព័ន្ធឯកសារឌីជីថលជំនាន់ទី ១ រួមជាមួយនឹងការចាក់បង្ហាញវីដេអូខ្លីស្តីពីអត្ថប្រយោជន៍ដែលនឹងទទួល

បានពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឯកសារឌីជីថល នៅរដ្ឋបាលស្រុក និង រដ្ឋបាលឃុំ, ដោយប្រព័ន្ធនេះនឹងជួយសម្រួលមួយកម្រិតបន្ថែមទៀត ដល់ការអនុវត្តថវិកានៅរដ្ឋបាលស្រុក និង រដ្ឋបាលឃុំ ដែលបច្ចុប្បន្ន រដ្ឋបាលស្រុក និង ឃុំ ត្រូវចំណាយពេលច្រើន ក្នុងការបញ្ជូនឯកសារជាក្រដាសមករតនាគារខេត្ត ហើយករណីមានកំហុសឆ្គងផ្សេងៗ ឯកសារជាក្រដាសនោះនឹងត្រូវបានរុញត្រឡប់ចុះឡើងជាយថាហេតុ ដើម្បីធ្វើការកែតម្រូវ ។ ជាមួយនឹងការអនុវត្តប្រព័ន្ធថ្មី, កិច្ចដំណើរការនេះនឹងត្រូវបានប្រែក្លាយជាការបញ្ជូនឯកសារជាលក្ខណៈឌីជីថលជំនួសវិញ ដែលនឹងធ្វើឱ្យមានផលចំណេញជាច្រើន, ទាំងពេលវេលា និង ថវិកា, ជាពិសេសនឹងជួយបង្កើននូវប្រសិទ្ធភាពនៃការអនុវត្តថវិកាសម្រាប់រដ្ឋបាលស្រុក និង ឃុំផងដែរ ។ រដ្ឋបាលស្រុកចំនួន ៧៥ និង រដ្ឋបាលឃុំចំនួន ១៨៥ នឹងចាប់ផ្តើមសាកល្បងប្រើប្រាស់ប្រព័ន្ធឯកសារឌីជីថលជំនាន់ទី ១ មុនគេ មុននឹងឈានទៅពង្រីកការប្រើប្រាស់ដល់រដ្ឋបាលស្រុក និង ឃុំផ្សេងទៀតនៅទូទាំងប្រទេស ។

ការរៀបចំឱ្យមានប្រព័ន្ធឯកសារឌីជីថលនេះ មិនមែនជាការចៃដន្យនោះទេ គឺជាការគិតគូរយ៉ាងច្បាស់លាស់ ផ្អែកតាមផែនការសកម្មភាពនៃ «**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ ២០១៩-២០២៥**» របស់រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយនឹងផែនការពង្រីកការអនុវត្តគម្រោង FMIS **ជំហានទី ៣** នៅក្នុងក្របខណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានការគិតគូរតម្រង់ទិសទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!**

អស់រយៈកាលជាង ២ ឆ្នាំកន្លងមកនេះ, យើងទាំងអស់គ្នាបានឃើញយ៉ាងច្បាស់នូវស្ថានភាពដែលកម្ពុជាត្រូវជួបប្រឈមនឹងវិបត្តិសុខភាពសាធារណៈសាកល ដែលកើតឡើងដោយការរីករាលដាលនៃជំងឺកូវីដ-១៩ ។ ទោះជាយ៉ាងនេះក្តី, យើងទាំងអស់គ្នាពិតជាមានសំណាងខ្លាំងណាស់ ដោយយើងមានការដឹកនាំដ៏ត្រឹមត្រូវ, ម៉ឺងម៉ាត់ និង ឈ្លាសវៃ ប្រកបដោយភាពប្រាកដនិយម និង ចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលសម្តេចបានដឹកនាំ និង ចង្អុលបង្ហាញដោយផ្ទាល់ លើសមរភូមិប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ រហូតដល់យើងទាំងអស់គ្នាបានចាកចេញពីវិបត្តិនេះដោយជោគជ័យ ជាមួយនឹងការដាក់ចេញនូវវិធានការសំខាន់ៗជាច្រើន ដើម្បីបើកដំណើរការប្រទេសពេញលេញ និង ជំរុញការស្តារសេដ្ឋកិច្ចឡើងវិញ ប្រកបដោយចីរភាព និង ភាពប្រកួតប្រជែងខ្ពស់ ។

ការបង្កើតឡើងនូវប្រព័ន្ធឌីជីថលខាងលើនេះ គឺជាសក្ខីភាពមួយនៃសមិទ្ធផលជាច្រើន ដែលរាជរដ្ឋាភិបាលបានសម្រេចនៅក្នុងកាលៈទេសៈដ៏លំបាកកន្លងមក ។ ស្របតាមអភិក្រម របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រែក្លាយវិបត្តិទៅជាកាលានុវត្តភាព, ការងារកែទម្រង់វិស័យ ហិរញ្ញវត្ថុសាធារណៈ មិនមានការបង្អង់ និង ដំណើរថយក្រោយនោះឡើយ ខណៈដែលប្រទេស ជាតិត្រូវជួបប្រឈម និង ពុះពារឆ្លងកាត់វិបត្តិកូវីដ-១៩, ជាពិសេស ការកសាង និង ចាប់យក ការប្រើប្រាស់ប្រព័ន្ធឌីជីថល ស្របតាមគន្លងថ្មីរបស់ពិភពលោក នៅក្នុងយុគសម័យឧស្សាហ-កម្ម ៤.០ ជាធ្នាក់ដ៏សំខាន់ក្នុងការសម្រួលដល់ការរស់នៅ, ការប្រកបអាជីវកម្ម និង ការអភិវឌ្ឍ ប្រទេសជាតិទាំងមូល ។ ក្នុងស្មារតីនេះ, ក្នុងនាមខ្ញុំជាប្រធានគណៈកម្មាធិការដឹកនាំការងារកែ ទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ខ្ញុំពិតជាមានក្ដីសោមនស្សរីករាយក្រៃលែង ដោយបានឃើញ នូវលទ្ធផលទាំងអស់នេះ ដែលជួយជំរុញដល់ការកែទម្រង់នានារបស់រាជរដ្ឋាភិបាល ឱ្យកាន់តែ ខិតកៀកទៅ រកគោលដៅដែលបានដាក់ចេញ ពិសេស ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ ។

**ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!**

ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាចលករដ៏មុតស្រួចរបស់រាជ-រដ្ឋាភិបាល ក្នុងការកែលម្អនូវប្រព័ន្ធគ្រប់គ្រងធនធានហិរញ្ញវត្ថុសាធារណៈរបស់ជាតិ ដែល មានដំណាក់កាលសំខាន់ៗចំនួន ៤ រួមមាន៖ (១)-**ភាពជឿទុកចិត្តបាននៃថវិកា**; (២)-**គណនេយ្យភាពហិរញ្ញវត្ថុ**; (៣)-**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**; និង (៤)-**គណនេយ្យភាពសមិទ្ធកម្ម** ដែលបច្ចុប្បន្ននេះ យើងកំពុងស្ថិតក្នុងដំណាក់កាលអន្តរកាលឈាន ពីដំណាក់ទី ៣ ទៅដំណាក់កាល ទី ៤ ដែលជាដំណាក់កាលចុងក្រោយ ។ ចាប់តាំងពី ដំណាក់កាលទី ២ មក, វត្តមាននៃប្រព័ន្ធ FMIS បានក្លាយជាចន្ទល់ និង ឧបករណ៍ដ៏ចាំបាច់ និង មិនអាចខ្វះបាន ក្នុងការគាំទ្រដល់ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ នៅ ក្នុងដំណាក់កាលនីមួយៗ និង ដោយមានការទទួលស្គាល់ពីស្ថាប័នអនុវត្តប្រព័ន្ធផ្ទាល់ រួមទាំង ដៃគូអភិវឌ្ឍន៍ មានជាអាទិ៍: សហភាពអឺរ៉ុប, មូលនិធិរូបិយវត្ថុអន្តរជាតិ, ធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អាស៊ី ចំពោះប្រសិទ្ធភាព និង ភាពចាំបាច់មិនអាចខ្វះបាននៃប្រព័ន្ធនេះ ។

រហូតមកដល់ពេលបច្ចុប្បន្ននេះ, ប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យប្រើប្រាស់នៅគ្រប់ អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ ពេញលេញ និង អង្គភាពសំខាន់ៗនៅតាមរាជធានី-ខេត្ត រួមមាន មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, រតនាគារ និង រដ្ឋបាលរាជធានី-ខេត្តទាំង ២៥ ស្របពេលជាមួយគ្នានឹងការអភិវឌ្ឍបន្ថែមមុខងារ

ថ្មីៗរបស់ប្រព័ន្ធជាបន្តបន្ទាប់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អង្គភាពប្រើប្រាស់ ។ គួររម្លឹកផងដែរថា, ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS កាលពីជំហានទី ១ និង ជំហានទី ២ គឺហាក់បីដូចជាដាក់បន្ទុកបន្ថែមដល់អ្នកអនុវត្ត ដោយសារតែមាននូវការតម្រូវឱ្យបន្តអនុវត្តការងារជាមួយឯកសារជាក្រដាសដដែលផង និង ការតម្រូវឱ្យបញ្ចូលទិន្នន័យ និង ដំណើរការនៅក្នុងប្រព័ន្ធផង ដែលនេះគឺជាដំណាក់កាលដ៏លំបាក សម្រាប់ការជំរុញចាប់យកការប្រើប្រាស់ប្រព័ន្ធ FMIS ទៅកាន់គ្រប់ភាគីពាក់ព័ន្ធ នៅក្នុងដំណើរការនៃការផ្លាស់ប្តូររបៀបធ្វើការងារ ។ ទោះជាយ៉ាងនេះ, ខ្ញុំសូមជម្រាបជូនថា កិច្ចការទាំងអស់នេះបានប្រព្រឹត្តទៅប្រកបដោយចក្ខុវិស័យវែងឆ្ងាយ ក្នុងគោលបំណងធានានូវការផ្លាស់ប្តូរជាជំហានៗ, ធានាបាននូវផលប៉ះពាល់ជាអប្បបរមា និង មានប្រសិទ្ធភាព ស្របតាមអភិក្រម **«ការផ្លាស់ប្តូរដោយការវិវត្ត, មិនមែនបដិវត្តន៍»**, ហើយជាលទ្ធផល, យើងទទួលបានមកវិញនូវការទទួលស្គាល់ពីប្រសិទ្ធភាព និង គុណតម្លៃនៃការប្រើប្រាស់ប្រព័ន្ធ FMIS ពីអ្នកប្រើប្រាស់ ។ ដូច្នេះ, យើងកំពុងតែបន្តអនុវត្តយ៉ាងសកម្មនូវ **ជំហានទី ៣** ដែលមានគោលដៅធំៗបន្ថែមថ្មីមួយចំនួនទៀតរួមមាន៖ ការពង្រីកវិសាលភាពនៃការប្រើប្រាស់ប្រព័ន្ធ FMIS ទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិ, គ្រឹះស្ថានសាធារណៈលក្ខណៈរដ្ឋបាល និង មន្ទីរជំនាញរាជធានី-ខេត្ត និង ការបង្កើនគណនេយ្យភាព និង ប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធ តាមរយៈការកែសម្រួលនីតិវិធីអនុវត្តការងារ, ឬ និយាយឱ្យខ្លី, ការលុបបំបាត់នូវការងារដោយដៃ មកជាការធ្វើការការងារតាមប្រព័ន្ធទាំងស្រុង ដែលស្របតាមជំហានយុទ្ធសាស្ត្រនេះ, បច្ចុប្បន្ន យើងបានដាក់ឱ្យអនុវត្តនីតិវិធីថ្មីតាមប្រព័ន្ធ FMIS ទាំងស្រុងទៅកាន់ ក្រសួង-ស្ថាប័នចំនួន ២៧ រួចហើយ លើការទូទាត់បៀវត្ស និង ការទូទាត់ចំណាយដែលមានវេទយិតភាពទាបមួយចំនួន ដោយគ្មានការប្រើប្រាស់ឯកសារជាក្រដាសទៀតឡើយ ។

ស្របនឹងផែនការពង្រីកការអនុវត្តគម្រោង FMIS ជំហានទី ៣, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក៏បានអភិវឌ្ឍបន្ថែមរួចរាល់នូវប្រព័ន្ធឯកសារឌីជីថលជំនាន់ទី ១ ដែលជាផ្នែកជំនួយរបស់ប្រព័ន្ធ FMIS សម្រាប់សម្រួលដល់ការងារមន្ត្រីនៃរដ្ឋបាលស្រុក និង ឃុំ ក្នុងការកាត់បន្ថយនូវការចរាចរឯកសារជាក្រដាសជាមួយរតនាគារខេត្ត ពាក់ព័ន្ធនឹងការអនុវត្តចំណូលចំណាយថវិកា ដោយជំនួសមកវិញនូវការបញ្ជូនឯកសារជាឌីជីថល តាមរយៈកម្មវិធីលើទូរសព្ទឆ្លាតវៃរបស់មន្ត្រីស្រុក និង ឃុំ ។ ដូចខ្ញុំបានលើកឡើងខាងដើម, ការប្រើប្រាស់ប្រព័ន្ធឌីជីថល គឺជាគន្លងការងារថ្មីរបស់រាជរដ្ឋាភិបាល; ដូច្នេះ, មន្ត្រីរាជការយើងត្រូវត្រៀមលក្ខណៈ

ឱ្យបានរួចរាល់ ក្នុងការចាប់យកឱ្យបាននូវការផ្លាស់ប្តូររបៀបរបបធ្វើការងារនេះ ក្នុងស្មារតីតាមឱ្យទាន់សម័យកាល និង ការវិវឌ្ឍនៃសង្គម និង សេដ្ឋកិច្ចឌីជីថល ។

ខ្ញុំលើកយកនូវប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាស់តឿនយើងទាំងអស់គ្នាថា **«ខ្ញុំយកឆ្នាំថ្មីនេះជំរុញកំណែទម្រង់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង អនុវត្តដោយម៉ឺងម៉ាត់ នូវច្បាប់ និង បទបញ្ញត្តិស្តីអំពីការប្រើប្រាស់ថវិកា»** ។ ក្នុងន័យនេះ, ខ្ញុំសង្ឃឹមថា មន្ត្រីគ្រប់ជាន់ថ្នាក់ទាំងអស់ដែលមានតួនាទី និង ភារកិច្ចក្នុងការបំពេញកិច្ចការគ្រប់គ្រងហិរញ្ញវត្ថុ និង ថវិកា នឹងខិតខំអភិវឌ្ឍសមត្ថភាពរបស់ខ្លួន ឱ្យស្របនឹងស្ថានការណ៍ដែលនឹងមានការផ្លាស់ប្តូរទាំងនេះ ព្រមទាំងប្តូរបេ្តជ្ញបំពេញភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ, ស្អាតស្អំ និង ប្រកបដោយវិជ្ជាជីវៈពិសេស សម្រាប់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

ក្នុងឱកាសដ៏មានតម្លៃនេះ, ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់ក្រុមការងារគ្រប់គ្រងគម្រោង FMIS រួមទាំង អគ្គនាយកដ្ឋានពាក់ព័ន្ធគន្លឹះៗនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលបានសហការគ្នា ក្នុងការកសាងបាននូវសមិទ្ធផលជាច្រើនកន្លងមក រួមទាំងសមិទ្ធផលដែលសម្រេចបាននៅក្នុងថ្ងៃនេះ និង ថ្លែងអំណរគុណដល់គ្រប់ក្រសួង-ស្ថាប័ន និង អង្គភាពនៅតាមរាជធានី-ខេត្តទាំងអស់ ចំពោះការចូលរួមគាំទ្រ និង កិច្ចសហការដ៏ជិតស្និទ្ធនាពេលកន្លងមក ដែលជាមូលហេតុនាំមកនូវភាពជោគជ័យទាំងអស់នេះ ។ ជាមួយគ្នានេះដែរ, ខ្ញុំក៏សូមលើកទឹកចិត្តឱ្យបន្តកិច្ចសហប្រតិបត្តិការនេះកាន់តែខ្លាំងក្លាថែមទៀត ដើម្បីនាំកម្ពុជាឈានឆ្ពោះទៅរកវឌ្ឍនភាព, ភាពសុខដុមរមនា និង វិបុលភាពកាន់តែចម្រុងចម្រើនរុងរឿងស្របតាមចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាល ។

នៅថ្ងៃប្រកបដោយសេចក្តីសោមនស្សក្រៃលែងនេះ, ខ្ញុំសូមផ្តល់នូវអនុសាសន៍មួយចំនួនដល់អង្គភាពដែលនឹងប្រើប្រាស់ប្រព័ន្ធឯកសារឌីជីថលជំនាន់ទី ១ និង អង្គភាពដែលគាំទ្រការប្រើប្រាស់ប្រព័ន្ធនេះ ដូចខាងក្រោម៖

(១)-រដ្ឋបាលស្រុក និង រដ្ឋបាលឃុំដែលត្រូវប្រើប្រាស់ប្រព័ន្ធ ត្រូវរៀបចំជាក្រុមការងារទទួលបន្ទុកប្រើប្រាស់ប្រព័ន្ធ, ក៏ដូចជាមន្ត្រីបង្គោលសម្រាប់ផ្តល់ព័ត៌មាន និង ស្នើការគាំទ្រនៅពេលជួបប្រទះបញ្ហានានា;

(២)-រតនាគារខេត្តត្រូវត្រៀមសហការយ៉ាងជិតស្និទ្ធ និង ជួយផ្តល់នូវការគាំទ្របន្ថែម ប្រកបដោយភាពប៉ុនប្រសកម្ម លើការប្រើប្រាស់ប្រព័ន្ធឱ្យគ្រប់ជ្រុងជ្រោយ និង ពន្យល់ឱ្យអស់សេចក្តីទៅកាន់រដ្ឋបាលស្រុក និង រដ្ឋបាលឃុំ ដែលជាអ្នកប្រើប្រាស់ប្រព័ន្ធ, និង

(៣)-ក្រុមការងារបច្ចេកទេសនៃលេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោង FMIS ត្រូវត្រៀមខ្លួនឱ្យបានរួចរាល់ ដើម្បីផ្តល់នូវការគាំទ្រប្រកបដោយភាពប៉ុនប្រសកម្ម និង ផ្តល់ព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធ ។

មុននឹងបញ្ចប់, ជាថ្មីម្តងទៀត, ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តម, លោកជំទាវ, លោក, លោកស្រី ព្រមទាំងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានចំណាយពេលដ៏មានតម្លៃ ចូលរួមក្នុងកម្មវិធីនាថ្ងៃនេះ ។

ជាទីបញ្ចប់, ខ្ញុំសូមប្រសិទ្ធពរជ័យជូនឯកឧត្តម, លោកជំទាវ, លោក, លោកស្រីទាំងអស់ ជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ និង ពលៈ** និង សូមជៀសឆ្ងាយពីជំងឺកូវីដ-១៩ ។

ខ្ញុំសូមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ «**ប្រព័ន្ធឯកសារឌីជីថលជំនាន់ទី ១** (FMIS Portal V1)» ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ!**